ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានពន្ធដារ
នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១៥៣៤ អពដ

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០១៣

# សេចក្តីជូនដំណឹង

## ស្តីពីកាតព្វកិច្ចសុំចុះបញ្ជីពន្ធដាររបស់អ្នកប្រកបអាជីវកម្មនិងអង្គការនានា

កន្លងមក អគ្គនាយកដ្ឋានពន្ធដារសង្កេតឃើញថាមានសហគ្រាស អ្នកប្រកបអាជីវកម្ម និងអង្គការមួយចំនួនមិនទាន់បានបំពេញកាតព្វកិច្ចចុះបញ្ជីពន្ធដារស្របតាមបទប្បញ្ញត្តិស្តីពីសារពើពន្ធនៅឡើយ។ អនុលោមតាមមាត្រាពាថ្មី មាត្រា១០១ នៃច្បាប់ស្តីពីសារពើពន្ធ និងមាត្រា២នៃអនុក្រឹត្យស្តីពីអាករលើតម្លៃបន្ថែម អគ្គនាយកដ្ឋានពន្ធដារសូមជម្រាបជូនដំណឹងដល់សហគ្រាស អ្នកប្រកបអាជីវកម្មទាំងអស់ និងអង្គការនានាជាអាទិ៍មាន អង្គការសាសនា អង្គការសប្បុរសធម៌ ឬអង្គការមិនស្វែងរកចំណេញ ។ល។ ត្រូវមានកាតព្វកិច្ចសុំចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធក្នុងរយៈពេល ១៥ថ្ងៃ ក្រោយពេលចាប់ផ្តើមអាជីវកម្មឬចាប់ផ្តើមធ្វើសកម្មភាព តាមរបបកំណត់ពន្ធដូចខាងក្រោម÷

**១- ការចុះបញ្ជីក្នុងរបបស្វ័យប្រកាស (របបពិត)**

ក្រុមហ៊ុន អ្នកប្រកបអាជីវកម្ម និងអង្គការដែលត្រូវសុំចុះបញ្ជីក្នុងរបបស្វ័យប្រកាស (របបពិត) គឺ ÷

ក. ក្រុមហ៊ុនគ្រប់ប្រភេទ និងអង្គការនានាដូចមានរៀបរាប់ខាងលើ

ខ. អ្នកប្រកបអាជីវកម្មក្រៅពីចំណុច “ក” ខាងលើ ដែលមានចំណូលប្រចាំឆ្នាំ ចាប់ពី៥០០លានរៀលឡើងទៅសម្រាប់ការលក់ទំនិញ ចាប់ពី២៥០លានរៀលឡើងទៅសម្រាប់ការផ្គត់ផ្គង់សេវា និងចាប់ពី ១២៥លានរៀលឡើងទៅសម្រាប់ការចុះកិច្ចសន្យាជាមួយរដ្ឋ។

**២- ការសុំចុះបញ្ជីក្នុងរបបម៉ៅការ**

អ្នកប្រកបអាជីវកម្មដទៃទៀតដែលមានចំណូលប្រចាំឆ្នាំតិចជាងកម្រិតចំណូលដែលត្រូវចុះបញ្ជីក្នុងរបបស្វ័យប្រកាសដូចមានចែងក្នុងចំណុច ១-ខ ខាងលើ ត្រូវសុំចុះបញ្ជីក្នុងរបបម៉ៅការ។

ក្នុងករណីមិនបានស្នើសុំចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធតាមរបបកំណត់ពន្ធខាងលើនេះទេ អ្នកប្រកបអាជីវកម្មឬអង្គការនឹងត្រូវទទួលរងទោសទណ្ឌតាមមាត្រា១២៨ និងមាត្រា ១៣៣ នៃច្បាប់ស្តីពីសារពើពន្ធ ដោយត្រូវបង់ពន្ធបន្ថែមចំនួន ២លានរៀល ចំពោះរបបស្វ័យប្រកាស (របបពិត) និងចំនួន ៥សែនរៀល ចំពោះរបបម៉ៅការ។ ជាមួយគ្នានេះដែរ អ្នកប្រកបអាជីវកម្មឬអង្គការ នឹងត្រូវទទួលរងការចុះបញ្ជីនិងការកំណត់ពន្ធជាឯកតោភាគីដោយរដ្ឋបាលសារពើពន្ធ តាមមាត្រា៩ និងមាត្រា១១ នៃអនុក្រឹត្យស្តីពីអាករលើតម្លៃបន្ថែម និងមាត្រា ១១៦ និងមាត្រា ១១៧ នៃច្បាប់ស្តីពីសារពើពន្ធ។ ការចុះបញ្ជីនិងការកំណត់ពន្ធជាឯកតោភាគី ត្រូវអនុវត្តចាប់ពីពេលដែលអ្នកប្រកបអាជីវកម្មឬអង្គការនានាត្រូវចុះបញ្ជីជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស (របបពិត) ដូចក្នុងចំណុច១ ខាងលើ និងចាប់ពីពេលមានសកម្មភាពចំពោះអ្នកប្រកបអាជីវកម្មជាអ្នកជាប់ពន្ធតាមរបបម៉ៅការ ដូចក្នុងចំណុច២ ខាងលើ ។

អគ្គនាយកដ្ឋានពន្ធដារ នឹងចុះត្រួតពិនិត្យ ផ្ទៀងផ្ទាត់ការចុះបញ្ជីនេះជាប្រចាំដល់ទីកន្លែង។

ក្នុងករណីមានចម្ងល់ សូមទាក់ទងជាមួយសាខាពន្ធដារខេត្ត-ខណ្ឌ ដែលទីតាំងអាជីវកម្មនិងអង្គការនានាស្ថិតនៅ។

អគ្គនាយកដ្ឋានពន្ធដារសង្ឃឹមនិងជឿជាក់ថា អ្នកប្រកបអាជីវកម្មនិងអង្គការនានា ពិតជាយកចិត្តទុកដាក់អនុវត្តតាមខ្លឹមសារនៃសេចក្តីជូនដំណឹងនេះ ឲ្យមានប្រសិទ្ធភាពខ្ពស់។

**អគ្គនាយកដ្ឋានពន្ធដារ**

អាគារកែងមហាវិថី សហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
CORNER RUSSIAN FEDERATION & MAO TSETONG BLVD. TOEK LAAK 1, TOUL KAUK, PHNOM PENH
ទូរស័ព្ទ: (៨៥៥) ២៣ ៨៨៦ ៧០៨ / ទូរសារ: (៨៥៥) ២៣ ៨៨៦ ៧០០
Phone: (855) 23 886 708/ Fax: (885) 23 886 700